# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 629

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការពន្លឿនការផ្សារភ្ជាប់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់ផ្លែឈើ បន្លែ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/22 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/24 |

៣. ចំណាយគម្រោងសរុប $1,597,600

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | Department of Agro-Industry |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានកសិ-ឧស្សាហកម្ម |

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការផ្សារភ្ជាប់នៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់បន្លែផ្លែឈើប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលធានាបាននូវគុណភាព សុវត្ថិភាពផលិតផល សម្រាប់តម្រូវការទីផ្សារ ពិតជាមានសារសំខាន់ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញនូវសេដ្ឋកិច្ចជាតិ តាមរយៈ ការជម្រុញការវិនិយោគ ការបង្កើនផលិតភាពកសិកម្មស្របតាមតម្រូវការទីផ្សារ ជាពិសេសបង្កើនប្រាក់ចំណូលជនបទ។ នេះជាផ្នែកមួយយ៉ាងសំខាន់ស្របនឹងការអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា (២០១៥-២០២៥) និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍនវិស័យកសិ-ឧស្សាហកម្ម។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍនវិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពង់ស្ពឺ, កណ្តាល, ព្រៃវែង, សៀមរាប, មណ្ឌលគីរី, តាកែវ, រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

១. ធ្វើឲ្យប្រសើរឡើងនូវរចនាសម្ព័ន្ធក្នុងផ្សារភ្ជាប់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់ផលិតផលផ្លែឈើបន្លែ
២. កសាងប្រព័ន្ធតាមដាននៃខ្សែច្រវាក់ផ្គត់ផ្គង់ផលិតផលផ្លែឈើបន្លែ
៣. ពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារ និងការចូលទីផ្សារនៃផលិតផលផ្លែឈើបន្លែ

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ផ្លែឈើ និងផ្លែឈើបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជម្រុញសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តភាព ដោយសារផលចំនេញច្រើនពីផលិតកកម្មនេះ និងបានចូលរួមចំណែកក្នុងការបង្កើនឪកាសការងារ និងជម្រុញកំណើនក្នុងវិស័យកសិកម្ម។ ទោះជាយ៉ាងនៅតែមានគំលាតធំរវាងតំរូវការ និងការផ្គត់ផ្គង់ដោយសារមានកត្តាចំបងៗមួយចំនួននៃបច្ចេទេសក្រោយពេលប្រមូលផលដែលបណ្តាលឲ្យផលិតផលមួយចំនួនត្រូវបាន បាត់បង់គុណភាព និងសុវត្ថិភាពតាមរយៈការគ្រប់គ្រងសីតុណ្ហភាព ការរក្សាទុក ការដឹកជញ្ជូន ការលើកដាក់ តម្លៃបន្ថែម និងជាពិសេសគ្មានប្រព័ន្ធគ្រប់គ្រងត្រជាក់នៃដំណើរខ្សែច្រវ៉ាក់ផ្គត់ផ្គង់។ មួយវិញទៀត ប្រជាកសិករមួយចំនួនធំអនុវត្តផលិតកម្មពុំមានផែនការច្បាស់លាស់ និងស្រមនឹងតម្រូវការទីផ្សារបច្ចុប្បន្ន។ គម្រោងនេះនឹងផ្តោតសំខាន់ទៅលើ៖

១. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងនៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់ផ្លែឈើនិងបន្លែដោយធានាបាននូវគុណភាព សុវត្ថិភាពផលិតផល និងកាត់បន្ថយនូវការបាត់បង់នៅកម្រិតតិចបំផុត
២. ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធត្រួតពិនិត្យនៃប្រភពដើមនៃផលិតផលផ្លែឈើ និងបន្លែ ដើម្បីធានាដល់ការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផល
៣. ជម្រុញដៃគូធុរកិច្ចកសិកម្មតាមរយៈការផ្តល់ព័ត៌មានជាក់លាក់អំពីតម្រូវការ និងការផ្គត់ផ្គង់ផលិតផលផ្លែឈើ និងបន្លែដើម្បីធានាដល់បរិមាណ តម្លៃ និងខាត់បង់ក្នុងកម្រិតតិចបំផុត

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

មានហេតុផលមួយចំនួនដែលគម្រោងនេះត្រូវបានជ្រើសរើស និងអទិភាព៖

១.ដំណើរនៃការផ្សារភ្ជាប់ខ្សែច្រវ៉ាក់ផ្គត់ផ្គត់នៅមានកម្រិតដែលបណ្តាលឲ្យផលិតផលរបស់កសិករភាគច្រើនលក់ នៅចំការ ឬតម្លៃនឹងធ្លាក់ចុះខ្លាំងនៅរដូវប្រមូលផល ព្រមទាំងការខាត់បង់យ៉ាងច្រើនតាមរយៈកង្វះបច្ចេកទេសក្រោយពេលប្រមូលផល រួមមានការរក្សាទុក ការលើកដាក់ ការដឹកជញ្ជូន ការចែកចាយ ការបន្ថែមតម្លៃ ដែលធ្វើឲ្យដំណើរនៃការផ្គត់ផ្គង់ផលិតផលផ្លែឈើ និងបន្លែថយចុះ និងប្រឈមនឹងបាត់បង់តម្លៃបន្ថែម ដែលធ្វើឲ្យកសិករ និងប្រតិករធុរកិច្ចកសិកម្មបាត់បង់នូវតម្លៃនៃផលិតផល និងឈានដល់ការបោះបង់នូវផលិតកម្ម។
២. បំរែបំរួលនៃតម្រូវក្នុងស្រុក និងប្រទេសជិតខាង និងនៅលើទីផ្សារអន្តរជាតិ
៣. ភាពជាដៃគូរវាងស្ថាប័នសាធារណៈនិងឯកជនពិតជាមានសារៈសំខាន់ក្នុងការជម្រុញការប្រកួតប្រជែង ប្រកបដោយនិរន្តភាព បរិយាប័ន្នក្នុងវិស័យកសិកម្ម

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះនឹងបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈ បង្កើនប្រាក់ចំណូល និងបង្កើនការងារជនបទ ដែលនឹងផ្តល់ផលប្រយោជន៍ផ្ទាល់ទៅដល់ កសិករ ឬអ្នកផលិតផល ប្រតិករធុរកិច្ចកសិកម្ម អ្នកកែច្នៃ និងអ្នកបរិភោគ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះបានចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់ទៅនឹងប្រជាជន និងបរិស្ថានជុំវិញតាមរយៈការកាត់បន្ថយនូវកាកសំណល់ ដែលបានពីផលិតផលខូចខាត់។ គម្រោងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងបង្កើនប្រាក់ចំណូលប្រជាជន ជាពិសេសនៅជនបទតាមរយៈបង្កើនការវិនិយោគនៅជនបទឲ្យកាន់តែមានប្រសិទ្ធិភាព។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សុំា**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ស្ត្រីមានសិទ្ធស្មើគ្នាការអនុវត្តការងារ និងបំពេញការងារក្នុងគម្រោង។ ក្នុងការអនុវត្តគម្រោងនេះស្ត្រីដែលមានសម្ថភាពនឹងត្រូវបានជ្រើសរើសជាអទិភាពក្នុងការអនុវត្តការងារ។ ម្យ៉ាងវិញទៀតគម្រោងនឹងជម្រុញឲ្យមានការចូលរួមពីស្ត្រីក្នុងគម្រោងនេះ មិនតិចជាង ៥០%។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**នាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានរចនាសម្ព័ន្ធ និងធនធានមនុស្សច្បាស់លាស់ដែលមានមន្ត្រី ជំនាញបច្ចេកទេសដោយបានបញ្ចប់ថ្នាក់បណ្ឌិត អនុបណ្ឌិត លើការគ្រប់គ្រងកសិពាណិជ្ជកម្ម ទីផ្សារ និងការវិភាពទីផ្សារ ការគ្រប់គ្រងគុណភាពសុវត្ថិភាពផលិតផលកសិកម្ម ទាំងក្នុងនិងក្រៅប្រទេស និងមានបទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងនេះ។**

**២៣. ហានិភ័យនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវិឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

គម្រោងនេះនឹងទទួលបានភាពជោគជ័យ និងលទ្ធផលផ្លែផ្កានៃរយៈពេលនៃការអនុវត្ត និងបានផ្តល់ផលជាវិជ្ជមានដើម្បីបន្តការអនុវត្តការងារបន្តបើទោះបីជាគម្រោងនេះត្រូវបានបញ្ចប់ ដោយសារគម្រោងអនុវត្ត និងគ្រប់គ្រងដោយមន្ត្រីជំនាញនាយកដ្ឋានកសិ ឧស្សាហកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងម្យ៉ាងវិញទៀតគម្រោងដែលបានលើកឡើងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធអភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ ឧស្សាហកម្មរបស់នាយកដ្ឋានកសិ ឧស្សាហកម្ម។ ទោះជាយ៉ាងណា មានបញ្ហាប្រឈមមួយចំនួនដល់ការពន្យាពេលនៃការអនុវត្តគម្រោង៖

១. ការធានាឲ្យចូលរួមយ៉ាងពេញទំហឹងនៃអ្នកពាក់ព័ន្ធសំខាន់នឹងការគ្រប់គ្រងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ចាប់ពីចំណុចចាប់ផ្តើមរហូតបញ្ចប់ការងារ

២. ការស្វែងយល់ និងការទទួលយកនូវចំណេះដឹង និងបច្ចេកវិទ្យាថ្មី

៣. ការប្រើប្រាស់នៃប្រភពធនធានមនុស្សដែលមានប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលទទួលបានពីគម្រោងជំនួយ សង្គមស៊ីវិល ជាដើម។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

ពុំទាន់មានម្ចាស់ជំនួយណាមួយក្នុងគម្រោងនេះនៅឡើយទេ។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 28.8 | 28.8 | 28.8 | 86.4 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 24.6 | 24.6 | 24.6 | 73.8 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 4.2 | 4.2 | 4.2 | 12.6 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 642.0 | 392.0 | 477.2 | 1,511.2 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 500.0 | 250.0 | 250.0 | 1,000.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 42.0 | 42.0 | 42.0 | 126.0 | 0.0 |
| ទិញសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 120.0 | 320.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 65.2 | 65.2 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយសរុប | 0.0 | 0.0 | 0.0 | 670.8 | 420.8 | 506.0 | 1,597.6 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 670.8 | 420.8 | 506.0 | 1,597.6 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: